ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង**
**ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម**

# របាយការណ៍
# ស្តីពី ការបូកសរុបលទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០១៨

## ១ ស្ថានភាពរួម

ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបងបានបំពេញការងារក្នុងតួនាទីជាភ្នាក់ងារសម្របសម្រួលក្នុងការបង្កើត និងជំរុញសហគមន៍កសិកម្ម ដែលបច្ចុប្បន្នសហគមន៍កសិកម្ម ក្នុងខេត្តបាត់ដំបងមានចំនួន ៨៤សហគមន៍ ស្ថិតនៅតាមបណ្តាស្រុក-ក្រុងទាំង ១៤ ។ ក្រៅពីការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្មជាអ្នកសម្របសម្រួល និងត្រួតពិនិត្យតាមដានដល់សហគមន៍កសិកម្មក៏មានអង្គការដៃគូអភិវឌ្ឍន៍នានាដែលបាននឹងកំពុងគាំទ្រដល់ការអភិវឌ្ឍន៍សហគមន៍កសិកម្មផងដែរ។ បណ្តាអង្គការទាំងនោះរួមមានៈ អង្គការទស្សនពិភពលោក, អង្គការការីតាស, អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍, អង្គការក្រុមអភិវឌ្ឍន៍ភូមិ, សមាគមដើម្បីអភិវឌ្ឍន៍សហគមន៍ខ្មែរជាដើម ។

ជាទូទៅសហគមន៍កសិកម្មមានមុខរបរចម្បងលើសេវាកម្មឥណទាន ដោយផ្តល់ប្រាក់កម្ចី និងទទួលប្រាក់សន្សំសម្រាប់សមាជិក។ មុខរបរសំខាន់មួយចំនួនទៀតដែលសហគមន៍កសិកម្មកំពុងដំណើរការរួមមានៈ ផ្គត់ផ្គង់ធាតុចូលកសិកម្ម, ទីផ្សារកសិផល, ផលិតកម្មដំណាំនិងសត្វ, ផលិតពូជស្រូវ, ឡសម្ងួតស្រូវ, លក់ប្រេងឥន្ធនៈ និងលក់គ្រឿងបរិភោគជាដើម ។

## ២ ស្ថានភាពបុគ្គលិក

មន្ត្រីបំពេញការងារនៅការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្មមានចំនួន ១១នាក់ ស្រីចំនួន ០៣នាក់ ។ មន្ត្រីការិយាល័យទាំងអស់មានប្រភេទក្របខណ្ឌ និងកម្រិតបណ្តុះបណ្តាលខាងក្រោមៈ

- ប្រភេទក្របខណ្ឌ(ក)ចំនួន ០២នាក់, ក្របខណ្ឌ(ខ)ចំនួន ០៣នាក់, ក្របខណ្ឌ(គ)ចំនួន ០៥នាក់, និងមន្ត្រីជាប់កិច្ចសន្យាចំនួន ០១នាក់
- ថ្នាក់អនុបណ្ឌិតចំនួន ០២នាក់, ថ្នាក់បរិញ្ញាបត្រចំនួន ០៥នាក់, ថ្នាក់មធ្យមចំនួន ០១នាក់, និងថ្នាក់បឋមចំនួន ០២នាក់ ។

ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម ក៏បានសហការជាមួយការិយាល័យកសិកម្មស្រុកទាំង១៣ និងក្រុង១ ដើម្បីរួមគ្នាជួយអភិវឌ្ឍសហគមន៍កសិកម្មតាមបណ្តាលស្រុក និងក្រុងផងដែរ ។

## ៣ សកម្មភាព និង លទ្ធផលសម្រេចបាន

### ក ការចុះបញ្ជីសហគមន៍កសិកម្ម

បានចុះបញ្ជីទទួលស្គាល់សហគមន៍កសិកម្មថ្មីចំនួន ០៣ គឺ៖

| ល.រ | ឈ្មោះ | ទីកន្លែង | លេខចុះបញ្ជី និងកាលបរិច្ឆេទ | សមាជិកសរុប | ចំនួនហ៊ុន | ដើមទុន (រៀល) |
|---|---|---|---|---|---|---|
| ១ | សហគមន៍កសិកម្មបាត់ដំបងមានជ័យ | ភូមិកំពង់ឆ្លង ឃុំវត្តតាមិម ស្រុកសង្កែ | ០៨៨ សក.បប/សកក ២៥/១២/២០១៧ | ៣៧នាក់ ស្រី ១៧នាក់ | ៧៤៨ | ៧៤,៨០០,០០ (១០០,០០០/ហ៊ុន) |
| ២ | សហគមន៍កសិកម្មកៅស៊ូគ្រួសារស្រុកសំឡូត | ភូមិព្រៃរំចេក ឃុំតាសាញ ស្រុកសំឡូត | ០៨៩ សក.បប/សកក ២៩/១២/២០១៧ | ១០២នាក់ ស្រី ៤៣នាក់ | ៤២២ | ២១,១០០,០០០ (៥០,០០០/ហ៊ុន) |
| ៣ | សហគមន៍កសិកម្មសង្កែ | ភូមិទួលល្វៀង ឃុំអូរដំបង២ ស្រុកសង្កែ | ០៩០ សក.បប/សកក ១៩/០៣/២០១៨ | ៧៣នាក់ ស្រី ៤២នាក់ | ៧៣ | ១,៤៦០,០០០ (២០,០០០/ហ៊ុន) |

### ខ ការចូលរួមមហាសន្និបាតសហគមន៍កសិកម្ម

ថ្នាក់ដឹកនាំការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម និងមន្ត្រីក្រោមឱវាទបានចូលរួមមហាសន្និបាតសហភាពសហគមន៍កសិកម្មបាត់ដំបងចំនួន ០១លើក និងសហគមន៍កសិកម្មចំនួន ១៣លើកក្នុងនោះ ៖

- ស្រុកសំឡូត ៖ សហគមន៍កសិកម្មតាគោកទល់ដែន, សម្រស់កំពង់ល្ពៅ, សំឡូតរតនផល, សំឡូតសាមគ្គី
- ស្រុកឯកភ្នំ ៖ សហគមន៍កសិកម្មរស្មីស្ដីក្រោម
- ស្រុកសង្កែ ៖ សហគមន៍កសិកម្មសង្កែ, បាឡាត់មានជ័យ
- ស្រុកមោងឫស្សី ៖ សហគមន៍កសិកម្មទឹកចិត្តកសិករគោរមានជ័យ
- ស្រុកបាណន់ ៖ សហគមន៍កសិកម្មកន្ទឺ១ភក្តីរស្មីជលសារ, កន្ទឺ២សាមគ្គីបាណន់មានជ័យ, ពន្លឺថ្មីក្ដីសង្ឃឹមនៃ កសិករ
- ស្រុកកំរៀង ៖ សហគមន៍កសិកម្មសាមគ្គីអូរដា, តាសែនចំរើនផល ។

### គ ការពង្រឹង និងតាមដានសហគមន៍កសិកម្ម

ថ្នាក់ដឹកនាំនិងមន្ត្រីសរុបចំនួន៤នាក់ បានចុះពង្រឹង និងតាមដានសហគមន៍កសិកម្មបានចំនួន ២១ ដូចខាងក្រោម៖

- ស្រុកបាណន់៖ សហគមន៍កសិកម្មកន្ទឺ១ភក្តីរស្មីជលសា, អាងកំពឹងពួយ, កន្ទឺ២សាមគ្គីបាណន់មានជ័យ, ពន្លឺមានចៃងមានជ័យ, និង បាណន់មានជ័យរស្មីប៉ែឡាំ
- ស្រុកសំឡូត៖ សហគមន៍កសិកម្មសំឡូតសាមគ្គី, សម្រស់កំពង់ល្ពៅ, សំឡូតរតនផល, មានជ័យរស្មីរុងរឿង
- ស្រុកសង្កែ៖ សហគមន៍កសិកម្មបាឡាត់មានជ័យ, ឃុំកំពង់ព្រៀង,មង្គលសាលាគ្រាវ
- ស្រុកគាស់ក្រឡ៖ សហគមន៍កសិកម្មគាស់ក្រឡភក្តីរស្មីរុងរឿង, ឆ្នាល់មាន់សាមគ្គី, ព្រះផុសពន្លឺថ្មី, ពន្លកថ្មី, ឆ្នាល់មាន់សាមគ្គីរុងរឿង, អមតធិបតី, រស្មីព្រៃភ្ញាស់ និង ពន្លឺសាមគ្គី
- ស្រុកថ្មគោល៖ សហគមន៍កសិកម្មតាសីសាមគ្គី ។

## ឃ ការដោះស្រាយទំនាស់ផ្ទៃក្នុងសហគមន៍កសិកម្ម

ថ្នាក់ដឹកនាំការិយាល័យបានដឹកនាំដឹកនាំគណៈប្រតិភូ លោក **ស៊្រុន សុខុម** អគ្គនាយករង នៃអគ្គយកដ្ឋានកសិកម្ម លោក **ជា សាំងដូណា** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម លោក **ម៉ុញ ឧត្តម** អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង ចូលរួមដោះស្រាយទំនាស់ផ្ទៃក្នុងរវាងសហគមន៍កសិកម្មពន្លឺថ្មីពេជ្រចិន្តា និងអ្នកស្រី អេង ស៊ីម អតីតបេឡាករសហគមន៍ ស្ដីពី បញ្ហាបាត់ថវិកាចំនួន ៤១,០៥៥,៧០០រៀល នៅសាលាស្រុកភ្នំព្រឹក ដោយបានសម្រេចឲ្យអ្នកស្រី អេង ស៊ីម សងប្រាក់ចំនួន ២០,០០០,០០០រៀលគត់ ក្នុងរយៈពេល ៦ឆ្នាំ ជំនួសប្រាក់ដែលបានបាត់ចំនួន ៤១,០៥៥,៧០០រៀល។

## ង ការពង្រឹងសមត្ថភាពមន្ត្រី

ថ្នាក់ដឹកនាំ និងមន្ត្រីការិយាល័យសរុបចំនួន ០២នាក់ បានចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី ប្រសិទ្ធភាពក្នុងការគ្រប់គ្រងវគ្គបណ្ដុះបណ្ដាល រយៈពេល ០២ថ្ងៃនៅខេត្តកំពង់ចាម ដែលរៀបចំដោយនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ។

## ច ការចូលរួមតាំងពិព័រណ៍

បានសម្របសម្រួលសហគមន៍កសិកម្មចូលរួមពិព័រណ៍បានចំនួន ០២លើកដូចខាងក្រោម៖

| ល.រ | ប្រធានបទពិព័រណ៍ | ចំនួនសហគមន៍ | ស្ថាប័ន/ គម្រោង | ទីកន្លែង |
|---|---|---|---|---|
| 1 | ពិព័រណ៍សម្ភារផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្នាក់ជាតិ ឆ្នាំ២០១៧ | ១ | ASPIRE | ភ្នំពេញ |
| 2 | ពិធីបុណ្យដារលាន | ១ | អគ្គនាយកដ្ឋានកសិកម្ម | ពោធិសាត់ |

## ឆ ការសហការ

បានសហការជាមួយអង្គការដៃគូអភិវឌ្ឍន៍ និងស្ថាប័នជំនាញចំនួន ០២ បានចំនួន ០៤លើក៖

- ការិយាល័យអប់រំ បណ្ដុះបណ្ដាល និងសហប្រតិបត្តិការអន្តរជាតិ បានចំនួន ០១លើក ក្នុងការសម្របសម្រួលសហគមន៍កសិកម្មចំនួន ១០ ឲ្យចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី របៀបសរសេររបាយាការណ៍ប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម ។
- អង្គការទស្សនពិភពលោកអន្តរជាតិកម្ពុជា បានចំនួន ០៣លើក ក្នុងការសម្របសម្រួលសហគមន៍កសិកម្មចំនួន ០៣ នៅក្នុងស្រុករុក្ខគិរី លើវគ្គបណ្ដុះបណ្ដាលស្រីពីខ្សែចង្វាក់តម្លៃទីផ្សារកសិផល ព្រមទាំងការរៀបចំក្រុមផលិតបន្លែសុវត្ថិភាព និងក្រុមចិញ្ចឹមមាន់ស្រែ។

## ជ ស្ថិតិសហគមន៍កសិកម្ម

តារាងសង្ខេបទិន្នន័យសហគមន៍កសិកម្មតាមក្រុង/ស្រុក

| ល.រ | ស្រុក/ក្រុង | ចំនួនសហគមន៍កសិកម្ម | សមាជិក | | អ្នកដឹកនាំ | | ដើមទុនបច្ចុប្បន្ន |
|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី | |
| 1 | មោងឫស្សី | 6 | 811 | 401 | 56 | 17 | 392,922,000 |
| 2 | ភ្នំព្រឹក | 6 | 662 | 338 | 49 | 22 | 885,694,300 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 3 | កំរៀង | 4 | 578 | 335 | 32 | 14 | 753,056,760 |
| 4 | សំពៅលូន | 5 | 700 | 454 | 37 | 17 | 794,393,480 |
| 5 | គាស់ក្រឡ | 8 | 1,334 | 720 | 76 | 24 | 447,917,200 |
| 6 | សង្កែ | 8 | 802 | 350 | 67 | 18 | 432,879,180 |
| 7 | ថ្មគោល | 8 | 550 | 327 | 66 | 22 | 114,844,740 |
| 8 | បវេល | 6 | 1,014 | 479 | 51 | 22 | 603,847,680 |
| 9 | បាណន់ | 11 | 1,679 | 963 | 93 | 30 | 1,319,016,720 |
| 10 | បាត់ដំបង | 2 | 152 | 123 | 13 | 8 | 60,926,000 |
| 11 | ឯកភ្នំ | 4 | 415 | 252 | 32 | 12 | 111,280,609 |
| 12 | រតនមណ្ឌល | 5 | 575 | 287 | 49 | 11 | 350,521,350 |
| 13 | សំឡូត | 7 | 1,864 | 1,243 | 73 | 32 | 925,399,620 |
| 14 | រុក្ខគិរី | 4 | 314 | 204 | 34 | 16 | 86,980,500 |
| | សរុប | 84 | 11,450 | 6,476 | 728 | 265 | 7,279,680,139 |

## ដ្យាក្រាមទី ១ ចំនួនសហគមន៍កសិកម្មផ្អែកតាមទំហំទ្រព្យសកម្មសរុប



### ដ្យាក្រាមទី ២ ចំនួនសហគមន៍កសិកម្មផ្អែកតាមប្រភេទទ្រព្យសម្បត្តិ




### ដ្យាក្រាមទី ៣ ចំនួនសហគមន៍កសិកម្មផ្អែកតាមប្រភេទមុខរបរ




## ៤ បញ្ហាប្រឈម

- សហគមន៍កសិកម្មខ្លះមានបញ្ហាលើដើមទុន ដោយសមាជិកខ្ចីមិនសងសហគមន៍
- ថ្នាក់ដឹកនាំសហគមន៍កសិកម្មមួយចំនួនអសកម្ម
- សហគមន៍កសិកម្មខ្លះមានមុខរបរតែមួយមុខ គឺការផ្តល់ឥណទានដល់សមាជិក
- សហគមន៍កសិកម្មខ្លះខ្វះបញ្ជីស្នាម ។

## ៥ ទិសដៅបន្ត

- ជួយអន្តរាគមន៍ដល់សហគមន៍កសិកម្មដែលជួបបញ្ហាត្រូវដោះស្រាយ
- បន្តសហការណ៍នឹងអង្គការនានា
- ជំរុញឲ្យសហគមន៍កសិកម្មរៀបចំរបាយការណ៍ប្រចាំឆ្នាំ
- ជំរុញ និងចូលរួមមហាសន្និបាតសហគមន៍កសិកម្ម
- ចុះពង្រឹង និងតាមដានដល់សហគមន៍កសិកម្ម
- ធ្វើបច្ចុប្បន្នភាពទិន្នន័យសហគមន៍ ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

បាត់ដំបង,ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨

អ្នករៀបចំរបាយការណ៍

ផុំ សុភក្ត្រា

បានឃើញ និងឯកភាព

**ប្រធានការិយាល័យ**

បានឃើញ និង ឯកភាព

ថ្ងៃ សុក្រ ៧កើត ខែ ចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

បាត់ដំបង,ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០១៨

**ប្រធានមន្ទីរ**

**ឈឹម_វជិរ**